# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការក្រសួងយុត្តិធម៌
លេខ ១៣៦០ ព្ររ.៣.២៦-៩៧

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**ជម្រាបមក**

**លោក ប្រធានតុលាការខេត្ត ក្រុង**

**លោកព្រះរាជអាជ្ញាអមតុលាការគ្រប់ខេត្ត ក្រុង**

**សូមជ្រាប។**

**កម្មវត្ថុ:** ពីការបង្កើតគណៈកម្មការដុតបំផ្លាញកញ្ឆា និងគ្រឿងញៀនផ្សេងៗទៀតដែលមានចែងក្នុងច្បាប់ ។

**យោង:** ដីកាលេខ ៣០ ដក.កច ចុះថ្ងៃទី១៨-០៧-៩៧ របស់សាលាខេត្តកំពង់ចាមស្តីពីការបង្កើតគណៈកម្មការដុតបំផ្លាញកញ្ឆា។

ខ្ញុំសូមជម្រាបអស់លោកថា ការបង្កើតគណៈកម្មការដុតបំផ្លាញគ្រឿងញៀនត្រូវអនុវត្តតាមមាត្រា៨៥ វាក្យខ័ណ្ឌទី៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនដែលបានចែងថាៈ ការបំផ្លាញចោលទាំងស្រុងនូវរុក្ខជាតិនិងសារធាតុផ្សេងៗត្រូវធ្វើភ្លាម និងតាមមធ្យោបាយសមស្របបំផុតនៅចំពោះមុខគណៈកម្មការដែលត្រូវបង្កើតឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

ដើម្បីអនុវត្តគោលការណ៍នៃច្បាប់ខាងលើនេះឱ្យបានសមស្រប ក្រសួងសូមអស់លោកប្រធាននឹងលោកព្រះរាជអាជ្ញាទូទាំងព្រះរាជាណាចក្រកម្ពុជា យកចិត្តទុកដាក់អនុវត្តតាមខ្លឹមសារនៃមាត្រា៨៥ខាងលើនេះឱ្យបានហ្មត់ចត់និងមានប្រសិទ្ធភាពខ្ពស់ដោយអនុវត្តតាមទម្រង់បែបបទនៃនីតិវិធី ដើម្បីធានាការបង្កើតគណៈកម្មការខាងលើនេះឱ្យបានត្រឹមត្រូវតាមបញ្ញត្តិច្បាប់នេះតទៅ ។ ក្រោយពីព្រះរាជអាជ្ញាបានធ្វើកំណត់ហេតុទទួលវត្ថុតាងជាគ្រឿងញៀនផ្សេងៗពីភ្នាក់ងារមានសមត្ថកិច្ចត្រូវធ្វើឱ្យបានត្រឹមត្រូវនិងហ្មត់ចត់តាមច្បាប់កំណត់ ។ ក្នុងករណីយល់ឃើញថា មិនត្រូវតម្កល់ទុកវត្ថុតាងទាំងនោះរហូតដល់តុលាការជំនុំជម្រះសេចក្តីជាស្ថាពរទេនោះ ព្រះរាជអាជ្ញាឬចៅក្រមស៊ើបអង្កេតឬចៅក្រមជំនុំជម្រះត្រូវតែប្រគល់ភារកិច្ចដុតបំផ្លាញវត្ថុតាងជាគ្រឿងញៀនផ្សេងៗទាំងនោះទេ ឱ្យគណៈកម្មការដែលមាននៅក្នុងប្រកាសលេខ ៦៣ ប្រក.៩៧ ចុះថ្ងៃទី០៤-០៩-១៩៩៧ របស់ក្រសួងយុត្តិធម៌ដើម្បីចាត់ចែងដុតបំផ្លាញចោលនិងដកហូតយកចំណែកណាមួយនៃវត្ថុតាងនេះ ជាសំអាងនៅពេលជំនុំជម្រះសម្រេចសេចក្តីតាមច្បាប់ ។

ហេតុនេះគណៈកម្មការត្រូវបង្កើតឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

អាស្រ័យហេតុនេះ សូមលោកប្រធានតុលាការនិងលោកព្រះរាជអាជ្ញាយកចិត្តទុកដាក់អនុវត្តសេចក្តីណែនាំខាងលើនេះឱ្យមានប្រសិទ្ធភាពខ្ពស់តទៅ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី០៤ ខែធ្នូ ឆ្នាំ១៩៩៧

**រដ្ឋមន្ត្រី**

**ចែម ស្ងួន**

<u>ចម្លងជូន</u>

-ក្រសួងមហាផ្ទៃ (នាយកដ្ឋានបង្ក្រាបគ្រឿងញៀន)
-អភិបាលខេត្ត-ក្រុង
-ស្នងការនគបាលខេត្ត-ក្រុង
-តុលាការនិងមហាអយ្យការអមតុលាការកំពូល
-សាលាឧទ្ធរណ៍និងមហាអយ្យការអមសាលាឧទ្ធរណ៍។
(ដើដើម្បីជ្រាប)